ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ..៤០៩៥.....អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤

**ជម្រាបជូន**

**លោក-លោកស្រី នាយក**

**អង្គការមូលនិធិគាំទ្រកុមារកម្ពុជា**

CAMBODIAN CHILDREN'S ADVOCACY FOUNDATION

**សកម្មភាព÷** មគ្គុទ្ទេសក៍សហគមន៍ អភិវឌ្ឍន៍សហគមន៍ និងកសិកម្ម

**អាសយដ្ឋាន÷** # 225 ផ្លូវ 2001 ភូមិ ប៉ប្រកខាងត្បូង សង្កាត់ កាកាប ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ

អនុលោមតាមមាត្រា១០១ មាត្រា១០២ និងមាត្រា ១០៣ នៃច្បាប់ស្តីពីសារពើពន្ធ និងប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ ខ្ញុំសូមជម្រាបជូនលោក-លោកស្រីជ្រាបថា អង្គការឬសមាគមរបស់លោក-លោកស្រីត្រូវបានធ្វើបច្ចុប្បន្នភាពព័ត៌មាននៅអគ្គនាយកដ្ឋានពន្ធដាររួចរាល់ហើយ និងត្រូវបានផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធថ្មី **K010-108012166** ដែលត្រូវយកទៅប្រើលើគ្រប់ឯកសារទាក់ទិននឹងពន្ធដារចាប់ពីថ្ងៃទី**១២ ខែមិថុនា ឆ្នាំ២០១៥ តទៅ។**

លោក-លោកស្រីត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ ឬបន្តដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ នៅ**សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ** តាមពេលវេលាកំណត់ដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ហើយត្រូវកាន់កាប់កត់ត្រាបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ចសារពើពន្ធ។

ក្នុងករណី លោក-លោកស្រីមិនបានដាក់លិខិតប្រកាសពន្ធ ឬដាក់លិខិតប្រកាសគ្មានសកម្មភាព ក្នុងរយៈពេលបីខែជាប់គ្នា អគ្គនាយកដ្ឋានពន្ធដារនឹងមានវិធានការលុបចោលការចុះបញ្ជីអង្គការឬសមាគមនេះភ្លាម ដោយអនុលោមតាមអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

សូមលោក-លោកស្រីនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ ទិបុល**

**ចម្លងជូន÷**
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈកម្មាធិការធីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- សាលារាជធានីភ្នំពេញ
- នាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ
- សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ
- នាយកដ្ឋានត្រួតពិនិត្យ
  "ដើម្បីជូនជ្រាប-មុខការ"
- ឯកសារ-កាលប្បវត្តិ